

# ជំនាញ និងការប្រែក្លាយក្នុងឧស្សាហកម្មនៅកម្ពុជា

សង្ខេបគោលនយោបាយកម្ពុជាស្តីពីជំនាញសម្រាប់ឧស្សាហកម្ម - លេខ ១២ (ឆ្នាំ២០១៩)

## ខ្លឹមសារសង្ខេប

ក្រុមហ៊ុនផលិតកម្មនៅកម្ពុជា ជាងពីរភាគបីមានកំណើន និងការប្រែក្លាយក្នុងប្រាំឆ្នាំកន្លងទៅនេះ។ កំណើនភាពទំនើបនិងស្មុគស្មាញនេះ ត្រូវការពលករដែលមានជំនាញខ្ពស់ ហើយកម្មវិធីអភិវឌ្ឍជំនាញវិជ្ជាជីវៈ (VSD programs) ដើរតួនាទីសំខាន់ក្នុងដំណើរការប្រែក្លាយក្រុមហ៊ុននានា នៅកម្ពុជា។ កម្មវិធី VSD មុនពេលចូលបម្រើការងារ អាចជាលក្ខខណ្ឌត្រូវមានចាំបាច់ សម្រាប់ការចូលបម្រើការងារប្រើជំនាញខ្ពស់ ព្រោះតាមធម្មតា និស្សិតកម្ពុជាទើបបញ្ចប់ការសិក្សា ពុំមានបទពិសោធន៍ធ្វើការក្នុងឧស្សាហកម្មជាក់លាក់ទេ ចំណែកឯកម្មវិធី VSD ដែលមានក្នុងពេលបម្រើការងារ ភាគច្រើនជាប់ទាក់ទងនឹងជំនាញសម្រាប់ឧស្សាហកម្មដ៏ជាក់លាក់។ គួរឲ្យស្តាយដែលកម្មវិធី VSD ភាគច្រើនមិនសូវមានផ្តល់ឲ្យពលករមានជំនាញទាប ដ៏ច្រើនលើសលុបនៅកម្ពុជានោះទេ ប៉ុន្តែពលករទាំងនេះ ត្រូវចូលរួមក្នុងកម្មវិធី VSD ដើម្បីកសាងទាំងជំនាញបច្ចេកទេស និងជំនាញទន់ (soft skills) ព្រោះកម្ពុជាមានគោលដៅលើកកម្ពស់ឧស្សាហកម្មរបស់ខ្លួន ក្នុងខ្សែសង្វាក់តម្លៃសកល។

## សេចក្តីផ្តើម

ឧស្សាហកម្មកម្មន្តសាលនៅកម្ពុជា ជាទូទៅប្រើពលកម្មច្រើន ហើយមានខ្សែសង្វាក់ផលិតកម្មមានតម្លៃបន្ថែមទាបដែលជំរុញឡើងដោយ វិនិយោគផ្ទាល់ពីបរទេស (FDIs)។ តាំងពីដើមទសវត្សរ៍១៩៩០ មក កម្ពុជាបានទាក់ទាញ FDI ដោយសារមានកម្រិតប្រាក់ឈ្នួលទាប កម្លាំងពលកម្មមានជំនាញទាប និងទទួលបាន លក្ខខណ្ឌអនុគ្រោះផ្នែកពាណិជ្ជកម្ម ស្របតាមឋានៈខ្លួនជាប្រទេសមានការអភិវឌ្ឍតិចនៅក្នុងចំណាត់ថ្នាក់របស់អង្គការសហប្រជាជាតិ។

ដោយសារកម្ពុជា មានផែនការក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ (តាមនិយមន័យរបស់ធនាគារពិភពលោក) នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ កម្ពុជាត្រូវតែងាកទៅខាងកម្មន្តសាលកម្មមានតម្លៃបន្ថែមខ្ពស់ ត្រូវបង្កើនសមត្ថភាពប្រកួតប្រជែង ប្រើបច្ចេកវិទ្យាកាន់តែទំនើប និងមានការតភ្ជាប់ជាមួយខ្សែសង្វាក់តម្លៃនៅក្នុងតំបន់ និងក្នុងពិភពលោក។ ក្នុងនេះផងដែរ ការអភិវឌ្ឍជំនាញដើរតួនាទីសំខាន់ណាស់។

អត្ថបទសង្ខេបគោលនយោបាយនេះ ពិនិត្យពីទំនាក់ទំនងរវាង VSD ជាមួយនឹង កំណើននិងការប្រែក្លាយឧស្សាហកម្ម ដោយប្រើទិន្នន័យបានពី អង្កេតកម្រិតសហគ្រាសដែលធ្វើឡើងកាលពីខែកញ្ញា ២០១៨ ដល់ មករា ២០១៩។

## ឧស្សាហកម្មមានកំណើន និងការប្រែក្លាយវិជ្ជមាន

ក្រុមហ៊ុនភាគច្រើន បានឆ្លើយសម្ភាសន៍ប្រាប់ថា ខ្លួនមានកំណើននិងការប្រែក្លាយវិជ្ជមាន[១] ពីឆ្នាំ២០១២ ដល់ ២០១៧។ រូបភាព១ បង្ហាញពី ចំនួនភាគរយនៃក្រុមហ៊ុនដែលបានរាយការណ៍ថាមានកំណើន និងនិន្នាការប្រែក្លាយរីកចម្រើន និងបង្ហាញទៀតថា ក្រុមហ៊ុនដែលមានកំណើនវិជ្ជមាន មានចំនួនច្រើនជាង ក្រុមហ៊ុនដែលមានការប្រែក្លាយវិជ្ជមាន។

បណ្តាក្រុមហ៊ុនមានកំណើនបៀវត្សរ៍វិជ្ជមាន គឺមានចំនួនភាគរយខ្ពស់បំផុត ដែលជាលទ្ធផលនៃកិច្ចប្រឹងប្រែងបង្កើនប្រាក់ឈ្នួលអប្បបរមា ក្នុងឧស្សាហកម្មវាយនភ័ណ្ឌ សម្លៀក




រូបភាព១៖ កំណើន និងការប្រែក្លាយ

បំពាក់ និងស្បែកជើង ក្នុងប្រាំឆ្នាំកន្លងមកនេះ។ ក្រុមហ៊ុនដែលមានបរិមាណលក់បានវិជ្ជមាន គឺមានចំនួនភាគរយខ្ពស់បំផុតលំដាប់ទី២ ហើយបន្ទាប់មកទៀតគឺ ក្រុមហ៊ុនដែលមានកំណើនការងារ។ និន្នាការនៃកំណើនបរិមាណលក់បាន ទំនងដើរស្របគ្នាជាមួយនឹងកំណើនការងារ ព្រោះក្រុមហ៊ុនតែងបង្កើនចំនួនកម្មករ ដើម្បីបំពេញតម្រូវការក្នុងផលិតកម្ម។ សម្រាប់ផលិតភាព ក្រុមស្រាវជ្រាវបានប្រើ បរិមាណលក់បានគិតក្នុងពលករម្នាក់ មកជំនួសវាក្នុងការគណនា ហើយតាមនេះ វាហាក់ដូចមានកំណើនវិជ្ជមានខ្ពស់ខ្លាំង។

លទ្ធផលស្រាវជ្រាវនេះក៏បង្ហាញដែរថា ក្រុមហ៊ុននានាមានការប្រែក្លាយគួរឲ្យកត់សំគាល់ក្នុងការកែលំអផលិតផល ការរៀបចំការងារ និងការប្រើបច្ចេកវិទ្យាទំនើបៈ ក្នុងនេះក្រុមហ៊ុនជាង ៧០% បានបញ្ជាក់ថា បានប្រែប្រួលកាន់តែទំនើបនិងស្មុគស្មាញឡើង។ ក្រុមហ៊ុនដែលមានផលិតផលមួយភាគធំបែបទំនើបនិងស្មុគស្មាញនោះ តែងតែមានទំនោរប្រើបច្ចេកវិទ្យាកាន់តែទំនើប និងមានការរៀបចំការងារនិងផលិតកម្មរបស់ខ្លួន។ ក្នុងនេះ ក្រុមហ៊ុនជាង ៨០% បានរាយការណ៍ថា ខ្លួនត្រូវការពលករមានជំនាញខ្ពស់មួយកម្រិតទៀត ឬខ្ពស់ខ្លាំងនៅពេលវិវត្តទៅមុខកាន់តែទំនើបនិងស្មុគស្មាញឡើង។

## ពលករមានជំនាញទាបកម្រទទួលបានកម្មវិធីអភិវឌ្ឍជំនាញវិជ្ជាជីវៈ

តារាង១ បង្ហាញពី ប្រភេទខុសៗគ្នានៃកម្មវិធី VSD នៅមុនពេល និងក្នុងពេលបម្រើការងារ និងចំនួនកម្មវិធី VSD ដែលក្រុមហ៊ុនវាយតម្លៃថា បានចូលរួមជួយបំពេញតម្រូវការផ្នែកជំនាញរបស់ខ្លួន។

ក្រុមហ៊ុនក្នុងវិស័យអគ្គិសនី និងអេឡិចត្រូនិក (E&E) មានកម្មវិធី VSD ខុសៗគ្នាច្រើនជាងគេ[២] ព្រោះវិស័យនេះត្រូវការពលករមកអនុវត្តការងារបច្ចេកទេស។ ក្រុមហ៊ុនក្នុងវិស័យកាត់ដេរមានកម្មវិធី VSD ប្រភេទខុសៗគ្នាច្រើនជាងគេលំដាប់ទី២ ហើយបន្ទាប់មកទៀតគឺ ក្រុមហ៊ុនក្នុងវិស័យកែច្នៃអាហារ។ លទ្ធផលអង្កេតបង្ហាញដែរថា ពលករជាទូទៅក្នុងផ្នែកទាំងបីនេះ ខ្វះខាតឱកាសទទួលបានកម្មវិធី VSD មុនពេលបម្រើការងារ រីឯអ្នកបច្ចេកទេស ប្រធានក្រុម និងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ក្នុងផ្នែក E&E និងការកែច្នៃអាហារមានឱកាសបែបនេះច្រើនជាង។ គួរកត់សំគាល់ថា ប្រធានក្រុមក្នុងផ្នែកកាត់ដេរពុំបានទទួលកម្មវិធី VSD មុនពេលបម្រើការងារទេ ព្រោះភាគច្រើនត្រូវបានតំឡើងឋានៈពីកម្មករទូទៅ ផ្អែកតាមលទ្ធផលនិងបទពិសោធន៍ការងារល្អ។

ភាគច្រើននៃកម្មវិធី VSD មុនពេលបម្រើការងារ ក្នុងផ្នែកទាំងបីខាងលើ សុទ្ធតែជាប់ទាក់ទងនឹងជំនាញអគ្គិសនីអេឡិចត្រូនិក និងអាហារ។ គេតែងយល់ឃើញទៀតថា កម្មវិធីទាំងនេះ មានលក្ខណៈទូទៅជាង ហើយទំនងអាចយកទៅប្រើជាគ្រឹះក្នុងផ្នែកជាច្រើនទៀត ដើម្បីកសាងជំនាញបន្ថែមពីលើនោះ។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុននានាវាយតម្លៃថា កម្មវិធី VSD មុនពេលបម្រើការងារទាំងអស់នេះ បានចូលរួមចំណែកច្រើនក្នុងការបំពេញតម្រូវការផ្នែកជំនាញរបស់ខ្លួន។

ក្រុមហ៊ុនក្នុងវិស័យកាត់ដេរបានរាយការណ៍ថា ខ្លួនមានកម្មវិធី VSD ប្រភេទខុសៗគ្នាក្នុងពេលបម្រើការងារច្រើនជាងគេ[៣] ហើយបន្ទាប់មកគឺ ក្រុមហ៊ុនក្នុងវិស័យកែច្នៃអាហារ និងអគ្គិសនីនិងអេឡិចត្រូនិក។ កម្មវិធីក្នុងពេលបម្រើការងារទាំងនេះជាប់ទាក់ទងនឹង ជំនាញខាងត្រួតពិនិត្យ អគ្គិសនី និងគ្រប់គ្រងនិងត្រួតពិនិត្យគុណភាព ហើយគេផ្តល់វាតាមវគ្គបណ្តុះបណ្តាលខ្លីៗ និងតាមធម្មតាសម្រាប់ពលករមានជំនាញខ្ពស់។ ដោយសារកម្មវិធីក្នុងពេលបម្រើការងារច្រើនតែផ្តោតលើជំនាញសម្រាប់ឧស្សាហកម្មជាក់លាក់នោះ ក្រុមហ៊ុននានាវាយតម្លៃថា កម្មវិធីក្នុងពេលបម្រើការងារទាំងនេះ បានចូលរួមចំណែកច្រើនក្នុងការបំពេញតម្រូវការផ្នែកជំនាញរបស់ខ្លួន។

ដូចមានបង្ហាញក្នុង តារាង១ ពលករទូទៅមិនទទួលបាន VSD ទេ ដោយសារពួកគាត់ជាទូទៅអនុវត្តការងារមានតម្លៃបន្ថែមទាប ដូចជា ការកាត់ ដេរ និងតម្រឹម (CMT) សម្រាប់ផ្នែកកាត់ដេរ, ការផ្គុំដំឡើងភាគច្រើនសម្រាប់វិស័យអគ្គិសនីនិងអេឡិចត្រូនិក, និងការវេចខ្ចប់ភាគច្រើន សម្រាប់ការកែច្នៃចំណីអាហារ។ ពលករទូទៅ និងប្រតិបត្តិករ តែងទទួលបានការណែនាំបង្ហាញការងារចំនួនពីរ-បីសប្តាហ៍ និងការបណ្តុះបណ្តាលភ្ជាប់នឹងការងារ ដោយមានជំនួយទ្រទ្រង់ពីប្រធានក្រុម និង/ឬ ប្រធានផ្នែកផលិតកម្ម។ ចំណុចគួរកត់សំគាល់គឺ ប្រភេទខុសៗគ្នានៃកម្មវិធី VSD មុនពេលបម្រើការងារ (១៦២) មានច្រើនជាង កម្មវិធីក្នុងពេលបម្រើការងារ (៥៣) ដែលបង្ហាញថា ក្រុមហ៊ុនភាគច្រើនមានវិនិយោគកម្រិតទាបលើ ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់បុគ្គលិកខ្លួន។

## ប្រភេទខុសៗគ្នានៃកម្មវិធី VSD មានផ្តល់ញឹកញាប់ជាងគេ មានទំនាក់ទំនងវិជ្ជមានជាមួយនឹងការប្រែក្លាយ ប៉ុន្តែមិនមែនជាមួយនឹងកំណើនទេ

ការវិភាគបង្ហាញថា ប្រភេទខុសៗគ្នានៃកម្មវិធី VSD មុនពេលបម្រើការងារ វាមានទំនាក់ទំនងវិជ្ជមានខ្លះៗជាមួយនឹងការកែលំអផលិតផល មានទំនាក់ទំនងវិជ្ជមានបង្គួរជាមួយនឹងការប្រើបច្ចេកវិទ្យាទំនើប និងមានទំនាក់ទំនងវិជ្ជមានខ្លះៗជាមួយនឹងការកែលំអរបៀបរៀបចំការងារ ប៉ុន្តែមិនមានទំនាក់ទំនងវិជ្ជមានគួរឲ្យកត់សំគាល់ជាមួយនឹង បរិមាណលក់ និងកំណើនបៀវត្សរ៍ទេ ហើយចំណុចនេះអាចបង្ហាញ

| វិស័យ/តួនាទី | កម្មវិធីមុនពេលបម្រើការងារ | | កម្មវិធីក្នុងពេលបម្រើការងារ | |
|---|---|---|---|---|
| | ប្រភេទខុសៗគ្នា * | ការចូលរួមចំណែកជាមធ្យម នៃកម្មវិធី VSD ដើម្បីបំពេញតម្រូវការផ្នែកជំនាញ | ប្រភេទខុសៗគ្នា * | ការចូលរួមចំណែកជាមធ្យម នៃកម្មវិធី VSD ដើម្បីបំពេញតម្រូវការផ្នែកជំនាញ |
| **អគ្គិសនី និង អេឡិចត្រូនិក (E&E)** | **58** | **ខ្លះៗ** | **7** | **ច្រើនគួរកត់សំគាល់** |
| ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ | 7 | ខ្លះៗ | 2 | ច្រើនគួរកត់សំគាល់ |
| អ្នកបច្ចេកទេស | 30 | ខ្លះៗ | 3 | ច្រើនគួរកត់សំគាល់ |
| ប្រធានក្រុម | 16 | ខ្លះៗ | 1 | ច្រើនគួរកត់សំគាល់ |
| ប្រតិបត្តិករ | 5 | ខ្លះៗ | 1 | ច្រើនគួរកត់សំគាល់ |
| ពលករទូទៅ | 0 | - | 0 | - |
| **ផ្នែកកាត់ដេរ** | **50** | **ច្រើនគួរកត់សំគាល់** | **30** | **ច្រើនគួរកត់សំគាល់** |
| ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ | 2 | ច្រើនគួរកត់សំគាល់ | 7 | ច្រើនគួរកត់សំគាល់ |
| អ្នកបច្ចេកទេស | 44 | ច្រើនគួរកត់សំគាល់ | 8 | ច្រើនគួរកត់សំគាល់ |
| ប្រធានក្រុម | 0 | - | 14 | ច្រើនគួរកត់សំគាល់ |
| ប្រតិបត្តិករ | 4 | ខ្លះៗ | 1 | ច្រើនគួរកត់សំគាល់ |
| ពលករទូទៅ | 0 | - | 0 | - |
| **ផ្នែកកែច្នៃអាហារ** | **54** | **ច្រើនគួរកត់សំគាល់** | **16** | **ច្រើនគួរកត់សំគាល់** |
| ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ | 10 | ច្រើនគួរកត់សំគាល់ | 4 | ច្រើនគួរកត់សំគាល់ |
| អ្នកបច្ចេកទេស | 27 | ច្រើនគួរកត់សំគាល់ | 7 | ច្រើនគួរកត់សំគាល់ |
| ប្រធានក្រុម | 8 | ច្រើនគួរកត់សំគាល់ | 5 | ច្រើនគួរកត់សំគាល់ |
| ប្រតិបត្តិករ | 9 | ច្រើនគួរកត់សំគាល់ | 0 | - |
| ពលករទូទៅ | 0 | - | 0 | - |
| **សរុប** | 162 | ច្រើនគួរកត់សំគាល់ | 53 | ច្រើនគួរកត់សំគាល់ |

**តារាង១៖** កម្មវិធី VSD មានញឹកញាប់ជាងគេ និងការចូលរួមចំណែកនៃកម្មវិធីក្នុងការបំពេញតម្រូវការផ្នែកជំនាញ

*ភាពខុសៗគ្នា៖ ក្នុងអត្ថបទនេះសំដៅដល់ ភាពខុសៗគ្នានៃកម្មវិធីដែលក្រុមហ៊ុនបានលើកឡើងញឹកញាប់ជាងគេ គឺ មិនមែនចំនួនជាក់ស្តែងនៃកម្មវិធី VSD ឬក៏ចំនួនភាគរយនៃបុគ្គលិកដែលបានចូលរួមក្នុងកម្មវិធីទាំងនោះទេ។

ថា បណ្តាក្រុមហ៊ុនដែល មានប្រភេទខុសៗគ្នានៃកម្មវិធីមុនពេលបម្រើការងារកាន់តែច្រើន ទំនងមានកម្រិតនៃការកែលំអផលិតផល និងរបៀបរៀបចំការងារខ្ពស់ជាងខ្លះ ហើយថែមទាំងមានកម្រិតបច្ចេកវិទ្យាខ្ពស់មធ្យម។

ការវិភាគក៏បានចង្អុលបង្ហាញផងដែរថា ប្រភេទខុសៗគ្នានៃកម្មវិធី VSD ក្នុងពេលបម្រើការងារ មានទំនាក់ទំនងជាវិជ្ជមានខ្លះៗ ជាមួយនឹងការកែលំអផលិតផល និងការប្រើបច្ចេកវិទ្យាទំនើប ប៉ុន្តែមិនមានទំនាក់ទំនងគួរឲ្យកត់សំគាល់ជាមួយនឹងការកែលំអ របៀបរៀបចំការងារ និងនិន្នាការនៃការលក់ឡើយ។ ចំណុចនេះបង្ហាញថា ក្រុមហ៊ុនដែលមានប្រភេទខុសៗគ្នាច្រើននៃកម្មវិធី VSD ក្នុងពេលបម្រើការងារ មានកម្រិតនៃការកែលំអផលិតផល និងការប្រើបច្ចេកវិទ្យាទំនើប កាន់តែប្រសើរជាងមុន។

បញ្ហាគួរឲ្យភ្ញាក់ផ្អើលដែលប្រភេទខុសៗគ្នានៃកម្មវិធី VSD ក្នុងពេលបម្រើការងារ មានទំនាក់ទំនងអវិជ្ជមានគួរឲ្យកត់សំគាល់ជាមួយនឹង កំណើនប្រៀវត្សរ៍ ប៉ុន្តែទិដ្ឋភាពនេះហាក់ដូចជាក្លែងក្លាយទេ ពីព្រោះកំណើនប្រៀវត្សរ៍អាចរងឥទ្ធិពលពីកត្តាជាច្រើន ដូចជា គោលនយោបាយរដ្ឋាភិបាលលើការកែតម្រូវប្រាក់ឈ្នួលអប្បបរមា ជាដើម មិនមែនមានតែកម្មវិធី VSD នោះឡើយ។

## សេចក្តីសន្និដ្ឋាន និងផលពាក់ព័ន្ធ

ក្រុមហ៊ុននានាដែលរាយការណ៍ថា ខ្លួនមានកំណើន និងប្រែក្លាយកាន់តែទំនើបនិងស្មុគស្មាញ គឺត្រូវការពលករមានជំនាញកាន់តែខ្ពស់។ ពលករមានជំនាញខ្ពស់ មានចំនួនភាគរយតិចនៅឡើយ នៅក្នុងកម្លាំងពលកម្មរបស់ក្រុមហ៊ុន ដោយកម្លាំងពលកម្មភាគច្រើននៅមានជំនាញទាប ហើយចំណុចនេះបញ្ជាក់ថា កម្ពុជាទំនងមានតម្រូវការតិចនៅឡើយនូវពលករមានជំនាញខ្ពស់ ដូច្នេះគួរពិនិត្យស្រាវជ្រាវថែមទៀតក្នុងការសិក្សាទៅអនាគត។

លទ្ធផលរកឃើញបង្ហាញថា កម្មវិធី VSD មុនពេលបម្រើការងារ អាចជាលក្ខខណ្ឌត្រូវមានជាមុន សម្រាប់ការចូលបម្រើការងារប្រើជំនាញខ្ពស់ ព្រោះនិស្សិតទើបបញ្ចប់ការសិក្សាពុំមាន បទពិសោធន៍ធ្វើការក្នុងឧស្សាហកម្មជាក់លាក់ទេ។ ដោយសារកម្មវិធីក្នុងពេលបម្រើការងារភាគច្រើន ជាប់ទាក់ទងនឹងជំនាញសម្រាប់ផ្នែកឧស្សាហកម្មជាក់លាក់ ដូច្នេះពលករត្រូវមានទាំងកម្មវិធីមុនពេល និងក្នុងពេលបម្រើការងារ ដើម្បីរួមចំណែក ជួយបំពេញតម្រូវការផ្នែកជំនាញរបស់ក្រុមហ៊ុន។ ការពង្រីកការផ្តល់កម្មវិធីមុនពេលបម្រើការងារ អាចជួយដោះស្រាយកង្វះខាតផ្នែកជំនាញ ហើយវិនិយោគកាន់តែច្រើនលើកម្មវិធីក្នុងពេលបម្រើការងារ ក៏អាចជួយដោះស្រាយបញ្ហានៃការជាប់ពាក់ព័ន្ធល្អ និងគុណភាពនៃកម្មវិធីមុនពេលបម្រើការងារដែរ ដើម្បីបំពេញតាមតម្រូវការនៅក្នុងឧស្សាហកម្ម។

ថ្វីបើពលករកម្ពុជាភាគច្រើនអាចចាត់ថ្នាក់បានថា មានជំនាញទាប ប៉ុន្តែកម្មវិធី VSD ភាគច្រើនមិនបានបម្រើដល់ការអភិវឌ្ឍជំនាញរបស់ពួកគាត់ទេ។ ពលករទាំងនេះមិនបានឆ្លងកាត់កម្មវិធីមុនពេល ឬក្នុងពេលបម្រើការងារឡើយ។ ទោះជាយ៉ាងណា គាត់ត្រូវចូលរួមក្នុងកម្មវិធី VSD ផ្សេងៗដើម្បីកែលំអទាំងជំនាញបច្ចេកទេស និងជំនាញទន់ គឺទន្ទឹមគ្នានឹង ឧស្សាហកម្មនៅកម្ពុជាដែលកំពុងបន្តឈានឡើង ក្នុងខ្សែសង្វាក់តម្លៃសកល។ ដូច្នេះ ដើម្បីជួយទ្រទ្រង់ដល់ពលករមានជំនាញទាប ត្រូវមានផ្តល់កម្មវិធី VSD ផ្សេងៗដើម្បីបង្កើនសមត្ថភាពជំនាញរបស់ពលករ ហើយអាចបំពេញបានតាមតម្រូវការផ្នែកជំនាញរបស់ឧស្សាហកម្ម។

ការសិក្សានេះពិនិត្យផ្ទៀងផ្ទាត់ឡើងវិញពី តួនាទីដ៏សំខាន់នៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីជួយក្រុមហ៊ុននានានៅកម្ពុជាឲ្យមានការប្រែក្លាយ ប៉ុន្តែមិនមែនឲ្យមានកំណើននោះទេ។ កំណើនអាចផុសចេញពីកត្តាផ្សេងទៀត ដូចជា តម្រូវការក្នុងទីផ្សារ និងគោលនយោបាយរដ្ឋាភិបាលលើប្រាក់ឈ្នួលជាដើម។ តាមនេះ ប្រភេទខុសគ្នានៃកម្មវិធី VSD អាចមានទំនាក់ទំនងជាប្រយោលជាមួយនឹង កំណើនតាមរយៈការប្រែក្លាយរបស់ក្រុមហ៊ុន ហើយការសិក្សាទៅអនាគតគួរពិនិត្យលំអិតថែមទៀតពីទំនាក់ទំនងជាប្រយោលនេះ។

## ប្រភព និងកំណត់សំគាល់

គម្រោងស្រាវជ្រាវពីជំនាញសម្រាប់ឧស្សាហកម្ម ដោយប្រើអង្កេតកម្រិតសហគ្រាស

១. កំណើនសំដៅដល់ ការរីកធំក្នុង បរិមាណលក់បាន ចំនួនការងារ និងបៀវត្សរ៍បុគ្គលិក ហើយ ការប្រែក្លាយសំដៅដល់ កំណើនផលិតភាព ការកែលំអផលិតផល ការប្រើបច្ចេកវិទ្យានិងម៉ាស៊ីនទំនើប និង ការកែលំអរបៀបរៀបចំការងារ។

២. កម្មវិធីទាំងនេះ គួរផ្តល់ឲ្យពលករមានជំនាញទាប មធ្យម និងខ្ពស់ មុនពេលចូលធ្វើការក្នុងផ្នែកឧស្សាហកម្មរបស់ខ្លួន។ កម្មវិធីរួមមាន ការបណ្តុះបណ្តាលរយៈពេលខ្លី និងការអប់រំបណ្តុះបណ្តាលកម្រិតខ្ពស់ផ្តោតលើឧស្សាហកម្មដែលនាំទៅដល់ ការបញ្ជាក់ទទួលស្គាល់បែបណាមួយ និងជំនាញសម្រាប់ផ្នែកឧស្សាហកម្មជាក់លាក់។

៣. កម្មវិធីទាំងនេះ គួរផ្តល់ឲ្យបុគ្គលិកមានជំនាញ ទាប មធ្យម ឬខ្ពស់ ក្រោយពេលបានចូលធ្វើការតាមផ្នែកឧស្សាហកម្មរៀងៗខ្លួន ប៉ុន្តែ ត្រូវបានផ្តល់ឡើងដោយ/ទទួលបានសេចក្តីបញ្ជាក់ពីភាគីទី៣ ដែលនាំទៅដល់ សមត្ថភាពជំនាញតាមផ្នែកឧស្សាហកម្មជាក់លាក់ផ្សេងៗ។

ប្រវត្តិ៖ សង្ខេបគោលនយោបាយនេះ ស្ថិតក្នុងឯកសារកំពុងចងក្រងមួយខ្សែ និងផ្អែកលើការស្រាវជ្រាវអនុវត្តឡើងក្នុងគម្រោង "ជំនាញសម្រាប់ឧស្សាហកម្ម" (phzh.ch/skillsforindustry) ដែលផ្តល់មូលនិធិដោយ Swiss Programme for Research on Global Issues for Development (កម្មវិធីស្វីសសម្រាប់ការស្រាវជ្រាវលើបញ្ហាសកលសម្រាប់ការអភិវឌ្ឍ)

អ្នកនិពន្ធ៖ រ៉ឹង ណារ៉ុន និង វ៉េន សីហា

អ្នកកែសម្រួល៖ Markus MAURER

ទំនាក់ទំនង៖ seyhah@cdri.org.kh & markus.maurer@phzh.ch

បោះពុម្ពផ្សាយដោយ៖ សាកលវិទ្យាល័យ Teacher Education Zurich និង វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅក្រុង Zurich (ស្វីស) និង ភ្នំពេញ (កម្ពុជា)

DOI: doi.org/10.5281/zenodo.3555183

(CC BY-SA 4.0)

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

FNSNF Swiss National Science Foundation

Swiss Programme for Research on Global Issues for Development